00746708

1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ~~០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស(អបជ)~~ 004/10-10-2011-ECCC/PTC (01)

ភាគីដាក់ឯកសារ: Nisha Valabhji មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Oct-2011, 11:10
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ [កោសលុប]

ចំណាត់ថ្នាក់ឯកសារដោយអង្គបុរេជំនុំជម្រះ សាធារណៈ [កោសលុប] Chanvath

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅក្នុងករណី ០០៤ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និង សុំឲ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធិភាពជូនជនសង្ស័យក្នុងករណី ០០៤**

---

<u>ដាក់ដោយ</u>៖

**មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី**

Nisha Valabhji

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៃតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងដំណើរការនីតិវិធី**

<u>ផ្ញើជូន</u>៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន

ចៅក្រម Rowan DOWNING

ចៅក្រម ន៉ី ធុល

ចៅក្រម Judge Chang-ho CHUNG

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

## I សេចក្តីផ្តើម

១. ការបន្តដំណើរការនីតិវិធីនៅក្នុងករណី ០០៤ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ("អបជ") ដោយគ្មានការចូលរួមប្រកបដោយប្រសិទ្ធិភាពពីមេធាវីការពារក្តី នឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនសង្ស័យ ដូចមានចែងនៅក្នុងវិធាន២១(១)នៃវិធានផ្ទៃក្នុងរបស់ អវតក ("វិធានផ្ទៃក្នុង")។

២. ជនសង្ស័យនៅក្នុងករណី ០០៤ មានសិទ្ធិទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាព ក្រោមវិធាន ២១(១) នៃវិធានផ្ទៃក្នុង ប៉ុន្តែបើតាមអង្គភាពគាំពារការការពារក្តីបានដឹង និងថ្វីបើមានការខិតខំប្រែងប្រែងទាំងអស់របស់ខ្លួនមកដល់ពេលនេះ ជនសង្ស័យនៅតែពុំទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពនៅឡើយទេ ។

៣. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី សូមស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះផ្អាកដំណើរការនីតិវិធី ដើម្បីអនុញ្ញាតឱ្យអង្គភាពគាំពារការការពារក្តីចាត់វាល់វិធានការចាំបាច់ទាំងអស់ ដើម្បីផ្តល់ការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពដល់ជនសង្ស័យនៅក្នុងករណី ០០៤ សម្រាប់គោលបំណងនៃដំណើរការនីតិវិធីទាំងនេះ និងបញ្ហាដទៃទៀតដែលអង្គជំនុំជម្រះយល់ឃើញថាស័ក្តិសម។

៤. បន្ថែមពីលើនេះទៀត មន្ត្រីទទួលបន្ទុកអង្គភាព DSS សូមស្នើដោយគោរពដល់អង្គបុរេជំនុំជម្រះបង្គាប់ឱ្យការិយាល័យរដ្ឋបាលផ្តល់អង្គភាពគាំពារការការពារក្តីនូវជំនួយផ្នែកភស្តុភារ និងជំនួយរដ្ឋបាលដែលចាំបាច់សម្រាប់ទាក់ទងជនសង្ស័យ និងជូនដំណឹងដល់ពួកគេអំពីសិទ្ធិរបស់ពួកគេ និងបង្ហាញដល់ពួកគេនូវបញ្ជីឈ្មោះមេធាវី ដោយអនុលោមតាមវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុង។ មន្ត្រីទទួលបន្ទុកអង្គភាព DSS សូមស្នើដោយគោរពដល់អង្គបុរេជំនុំជម្រះឱ្យផ្តល់ការិយាល័យរដ្ឋបាលនូវព័ត៌មានណាមួយដែលខ្លួនមាន ដែលអាចពន្លឿនដំណើរការនេះ ។

៥. នៅដំណាក់កាលអន្តរកាលនេះ មន្ត្រីទទួលបន្ទុកអង្គភាព DSS សូមស្នើដោយគោរពឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាបង្គាប់ឱ្យអនុប្រធានការិយាល័យរដ្ឋបាលធ្វើតាមសំណើរបស់អង្គភាពគាំពារការការពារក្តីដែលបានស្នើសុំឱ្យបន្តកិច្ចសន្យាការងារដល់ [redacted] មេធាវីដែលចាត់តាំងដោយអង្គភាពគាំពារការការពារក្តីដើម្បីការពារផលប្រយោជន៍របស់ជនសង្ស័យរហូតដល់ពួកគេត្រូវបានចាត់តាំងមេធាវីរៀងៗខ្លួនតាមការជ្រើសរើស ដោយខ្លួនឯង ។

៦. មន្ត្រីទទួលបន្ទុកអង្គភាព DSS សូមជម្រាបដោយគោរពដល់អង្គបុរេជំនុំជម្រះដោយថានាងបាន

ដាក់សំណើមួយ សុំផ្អាកដំណើរការនីតិវិធីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ("សចស")[1] ដែលដាក់ភ្ជាប់មកជាមួយញត្តិនេះជាឧបសម្ព័ន្ធ ក និងសំណើសុំជំនួយពី ការិយាល័យរដ្ឋបាល[2] ដែលដាក់ភ្ជាប់ជាមួយញត្តិនេះជាឧបសម្ព័ន្ធ ខ ។

## II. ការសង្ខេបអង្គហេតុដែលពាក់ព័ន្ធ

### ២.១ ដំណើរការនីតិវិធីនៅក្នុងករណី 00៤ ប៉ះពាល់ដល់ផលប្រយោជន៍របស់ជនសង្ស័យ

៧. សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២00៩ បានចេញសេចក្តីប្រកាសព័ត៌មានបញ្ជាក់ពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរនៅសហចៅក្រមស៊ើបអង្កេត[3]។

៨. នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានប្រកាសពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមនៅក្នុងករណី00៤[4]។

៩. នៅថ្ងៃទី ៨ ខែសីហា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីប្រកាសព័ត៌មានមួយដោយបានបញ្ជាក់នូវបញ្ជីយ៉ាងវែងនៃទីកន្លែងបទល្មើស និងព័ត៌មានអំពីឧក្រិដ្ឋកម្មជាច្រើនដែលស្ថិតនៅក្រោមការស៊ើបអង្កេតនៅក្នុងករណី 00៤[5] ។

---

[1] 00៤/0៧-0៩-២00៩-អវតក/កសចស "សំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅក្នុងករណី 00៤ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងសុំវិធានការនានាទាក់ទងនឹងតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពដល់សង្ស័យនៅក្នុងករណី 00៤ ចុះថ្ងៃទី៧ ខែតុលាឆ្នាំ២០១១ (ឧបសម្ព័ន្ធ ក) ។ ដោយសារបញ្ហាបច្ចេកទេសទាក់ទងនឹងការដាក់ឯកសាតាមអេឡិកត្រូនិក បានរាំងអង្គភាពគាំពារការការពារក្តីមិនអាចដាក់សំណើនេះនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១១ បាន ។

[2] អនុស្សរណៈ "អង្គភាពគាំពារការការពារក្តីបង្ហាញបញ្ជីឈ្មោះមេធាវីជាតិ និងអន្តរជាតិដល់ជនសង្ស័យនៅក្នុងករណី 00៤ ដោយស្របតាមវិធាន ២១(២)(ង) នៃវិធានផ្ទៃក្នុង, Nisha Valabhji (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្តី) ចុះថ្ងៃទី៧ ខែ តុលា ឆ្នាំ២០១១ (ឧបសម្ព័ន្ធ ខ) ។

[3] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី, ការិយាល័យសហព្រះរាជអាជ្ញានៃ អវតក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២00៩ ។

[4] សេចក្តីប្រកាសព័ត៌មាន: សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងករណី 00៤ ចុះថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ២០១១ ។

[5] សេចក្តីប្រកាសព័ត៌មាន "សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណី 00៤ (00៤/0៧-0៩-២00៩-អវតក/កសចស) ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១

១០. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១១ [redacted] បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី ០០៣ និង ០០៤[6]។

១១. នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ លោក Rob HAMILL បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី ០០៣ និង០០៤[7] ។

១២. នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១១ តំណាងផ្លូវច្បាប់របស់លោក Rob HAMILL បានដាក់សំណើសុំចូលមើលសំណុំរឿង ០០៣ និង ០០៤[8] ។

១៣. នៅថ្ងៃទី១៦ ឧសភា ឆ្នាំ២០១១ លោក Rob HAMILL បានស្នើសុំពន្យាកាលបរិច្ឆេទសម្រាប់ដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើរបស់គាត់ សុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី ០០៤ ដោយរង់ចាំការសម្រេចលើសំណើរបស់គាត់សុំចូលមើលសំណុំរឿង ០០៤[9]។

១៤. នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ [redacted][10] និងនៅថ្ងៃទី២៣ ឧសភា ឆ្នាំ២០១១ លោក Rob HAMILL[11] បានដាក់បណ្ដឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតបដិសេធពាក្យសុំរបស់ពួកគេ ដើម្បីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី ០០៤ ។

---

[6] ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ០១) "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [redacted] ឯកសារ D5/1/4/1 (ERN: 00698346) នៅកថាខណ្ឌទី១ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១១ ។

[7] ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ០១) "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ Rob HAMILL (D11/2/3) (ករណី០០៣ និង០០៤) ឯកសារ D5/2/4/2 (ERN: 00693830) ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១១ ។ ឯកសារត្រូវបានចាត់ថ្នាក់ជាសម្ងាត់ ហើយត្រូវបានបញ្ជូនមកអង្គភាព DSS ដោយមន្ត្រីសំណុំរឿងនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ ។

[8] ដូចខាងលើ នៅកថាខណ្ឌទី ៦ ។

[9] ដូចខាងលើ នៅកថាខណ្ឌទី ៧ ។

[10] សូមមើលខាងលើ នៅអក្សរក្នុងលេខយោងទី៦ ។

[11] សូមមើលខាងលើ នៅអក្សរក្នុងលេខយោងទី៧ ។

00746712





១៥. នៅថ្ងៃទី៨ សីហា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីប្រកាសព័ត៌មានមួយ ដោយបានបញ្ជាក់ថាបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០០ ពាក្យសុំ[12]។

១៦. នៅក្នុងរបាយការណ៍តុលាការខែសីហា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា បានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណី ០០៤ ជាង ៣០០៤ ពាក្យសុំ ដែលមានកម្រាស់ ៥០,០០០ សន្លឹក និងមានផែនការចុះទៅមូលដ្ឋានទាក់ទងទងនឹងករណី០០៤ ទៀតផង[13]។

## ២.២ ជនសង្ស័យនៅតែមិនទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពនៅឡើយ

១៧. នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១០ អតីតប្រធានអង្គភាពគាំពារការការពារក្តី លោក Richard Rogers បានស្នើសុំការអនុញ្ញាតចូលមើលសំណុំរឿង ០០៣ និង ០០៤ ក្នុងគោលបំណងការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងដើម្បីរៀបចំការពារក្តីប្រកបដោយប្រសិទ្ធិភាពសម្រាប់ជនសង្ស័យនៅក្នុងករណីទាំងពីរនេះ[14] ។

១៨. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបនៅក្នុងលិខិតមួយ ដោយបានបដិសេធចោលសំណើនេះ[15]។ ប៉ុន្តែលិខិតនេះមិនបានលើកឡើងនូវបញ្ហានៃការចាត់តាំងមេធាវីការពារក្តីក្នុងករណី ០០៣ និង ០០៤ ទេ ហើយទោះជាក្នុងករណីណាក៏ដោយ លិខិតនេះមិនបានអះអាង ឬបញ្ជាក់ន័យថាជា "ដីកាសម្រេច" ដែរ[16] ។

---

[12] សូមមើលខាងលើ នៅអក្សរក្នុងលេខយោងទី២ ។របាយការណ៍តុលាការខែសីហា ឆ្នាំ២០១១ លើកឡើងថាមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាង ៣០០ ពាក្យសុំ បានទទួលនៅក្នុងករណី ០០៤ "របាយការណ៍តុលាការៈ ខែសីហា ២០១១" ផ្នែកកិច្ចការសាធារណៈ, លេខ ៣៩ នៅទំព័រ ៥ ។

[13] "របាយការណ៍តុលាការៈ ខែសីហា ២០១១" ផ្នែកកិច្ចការសាធារណៈ, លេខ ៣៩ នៅទំព័រ ៥ ។

[14] លិខិតៈ កម្មវត្ថុ "សិទ្ធិការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤" ដោយ R.J Rogers (ប្រធាន DSS) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ។

[15] លិខិតៈ កម្មវត្ថុ "សិទ្ធិការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤" ដោយ យូ ប៊ុន ឡេង និង Marcel Lemond, ឯកសារ A1/2 (ERN 00611316) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ , ត្រូវបានចាត់ចំណាត់ជាឯកសារសម្ងាត់ និងជូនដំណឹងដល់អង្គភាពគាំពារការការពារក្តី នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០។

[16] អនុលោមតាមយុត្តិសាស្ត្ររបស់ អវតក លិខិតរបស់សហចៅក្រមស៊ើបអង្កេតមិនអាចបង្កើតបានជាដីកាសម្រេច ឬដីកាបង្គាប់ដែលចងកាតព្វកិច្ចឱ្យអនុវត្តបានទេ ។ សូមមើលការពិភាក្សាស្តីពីភាពខុសគ្នាអត្ថន័យផ្នែកច្បាប់រវាង"លិខិត" និង"ដីកា

សំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅក្នុងករណី ០០៤ នៅចំពោះអង្គបុរេជំនុំជម្រះ និងសុំឱ្យមាន

១៩. នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១០ អតីតប្រធានអង្គភាពគាំពារការការពារក្តី បានបញ្ជូនអនុស្សរណៈមួយទៅការិយាល័យរដ្ឋបាល ដោយបានស្នើសុំឱ្យផ្តល់[redacted] តាមលក្ខន្តិកៈការងារក្នុងចំណោមបញ្ហាដទៃទៀត ដូចខាងក្រោម:

ទីប្រឹក្សា[redacted] ([redacted] Consultant) គឺត្រូវការចាំបាច់ដើម្បីជួយអង្គភាពគាំពារការពារក្តីនៅក្នុងករណី ០០៣ និង០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមរយៈ:

- ការតំណាងឱ្យផលប្រយោជន៍របស់ជនសង្ស័យដែលមិនបង្ហាញអត្តសញ្ញាណ ដើម្បីធានាដល់ការគោរពសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។
- ផ្តល់ការប្រឹក្សា និងជំនួយដទៃទៀតដែលតម្រូវ នៅមុនពេលដែលសហមេធាវីត្រូវបានចាត់តាំងឱ្យជនសង្ស័យនិមួយៗនៅពេលណាមានការយកចម្លើយ ឬ ចាប់ខ្លួន[17] ។

២០. អនុប្រធានការិយាល័យរដ្ឋបាលយល់ព្រមលើកិច្ចសន្យាការងាររបស់[redacted] ហើយ[redacted] បានចុះហត្ថលេខាលើកិច្ចសន្យាការងាររបស់គាត់ និងចាប់ផ្តើមបំពេញការងារនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១០[18]។

២១. នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១០ អតីតប្រធានអង្គភាពគាំពារការការពារក្តី បានចាត់តាំង[redacted] ជាមេធាវីតំណាងឱ្យផលប្រយោជន៍របស់ជនសង្ស័យមិនបង្ហាញអត្តសញ្ញាណនៅក្នុងករណី ០០៣ និង ០០៤ រហូតដល់ពួកគេត្រូវបានចាត់តាំងមេធាវីរៀងៗខ្លួន តាមការជ្រើសរើសដោយខ្លួនឯង ។ ការចាត់តាំងនេះត្រូវបានបញ្ជាក់ជាលាយលក្ខណ៍អក្សរជាផ្លូវការដោយអង្គភាពគាំពារការការពារក្តីដល់លោក គង់ សំអុន នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១០[19] និងបានជូនដំណឹងទៅសហចៅ

---

សម្រេច" នៅក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អវតក-កសចស, សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការរំលោភការសម្ងាត់នៃកិច្ចស៊ើបសួរ" របស់អង្គបុរេជំនុំជម្រះ ឯកសារ D138/1/8 (ERN 00349456) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ នៅកថាខណ្ឌទី ៤៣-៤៤ ។

[17] អនុស្សរណៈ "Consultancy: គង់ សំអុន" ពីលោក Richard Rogers (ប្រធានអង្គភាព DSS) ទៅកាន់ Emmanuelle Dupont (ប្រធានផ្នែកបុគ្គលិក នៃUNAKRT ) ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១០ ។

[18] កិច្ចសន្យាសម្រាប់ទីប្រឹក្សាលេខ ៤៩៨២, ចុះហត្ថលេខាដោយ [redacted] (ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១០) និង[redacted](ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ២០១០) ។

[19] "លិខិតចាត់តាំង" ដោយ [redacted] (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្តី) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ ។

ក្រុមស៊ើបអង្កេតនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១[20] ។

២២. សហចៅក្រមស៊ើបអង្កេត មិនបានទាក់ទងមកអង្គភាពគាំពារការការពារក្ដីទាក់ទងនឹងការជូនដំណឹងពីការចាត់តាំងនេះទេ ។ ក្នុងសេចក្ដីសម្រេចលើញត្តិដែលដាក់ដោយ [redacted] សហចៅក្រមស៊ើបអង្កេតបានហៅ [redacted] ថាជា "មេធាវីការពារផលប្រយោជន៍ជនសង្ស័យមិនបង្ហាញអត្តសញ្ញាណ" ។ សេចក្ដីសម្រេចនេះបានចេញបន្ទាប់ពីការជូនដំណឹងអំពីការចាត់តាំងនេះ[21] ។

២៣. កិច្ចសន្យាការងារលើកដំបូងរបស់ [redacted] ផុតកំណត់នៅថ្ងៃទី៣០ មេសា ឆ្នាំ២០១១ ។ មន្ត្រីទទួលបន្ទុកអង្គភាព DSS បានបញ្ជូនអនុស្សរណៈចំនួនពីរទៅអនុប្រធានការិយាល័យរដ្ឋបាល គឺមួយនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១[22] និងមួយទៀតនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១[23] ស្នើសុំឱ្យបន្តកិច្ចសន្យាការងាររបស់ [redacted] ។

២៤. អនុប្រធានការិយាល័យរដ្ឋបាលមិនយល់ព្រមបន្តកិច្ចសន្យានេះទេ ហើយបានស្នើឱ្យអង្គភាពគាំពារការការពារក្ដីផ្ដល់ការពន្យល់ និងអំណះអំណាងបន្ថែមទៀត។ ដើម្បីអនុវត្តតាមការស្នើសុំនេះ អនុស្សរណៈទីបី ត្រូវបានដាក់ទៅអនុប្រធានការិយាល័យរដ្ឋបាលនៅថ្ងៃទី៦ កក្កដា ឆ្នាំ២០១១[24]។

---

[20] កម្មវត្ថុ: "ការជូនដំណឹងពីការចាត់តាំង"-សំណុំរឿង ០០៣ និង ០០៤ ដោយ Rupert Abbott (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្ដី) ឯកសារ A2(ERN 0064132) ចុះថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០១១ ។ (ត្រូវបានចំណាត់ថ្នាក់ជាឯកសារសម្ងាត់ និង ជូនដំណឹងមកអង្គភាព DSS នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១១)។

[21] ០០៤/០០៧-០៩-២០០៩-អវតក-កសចស "កោលលុបចោលចំណាងជើង", សហចៅក្រមស៊ើបអង្កេត, ឯកសារ D4/1 (ERN 00658678) ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១- [redacted] មកអង្គភាព DSS ដោយលោក គង់ សំអុន នៅក្នុងឯកសារគាំទ្រដើម្បីការទាមទារប្រាក់កម្រៃសម្រាប់ការធ្វើកិច្ចការ [redacted]

[22] អនុស្សរណៈ: "អង្គភាពគាំពារការការពារក្ដី-សំណើសុំបន្តកិច្ចសន្យា consultancy សម្រាប់ [redacted] ដោយអ្នកនាង Nisha Valabhji (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្ដី) ចុះថ្ងៃទី៣ ខែ ឧសភា ឆ្នាំ២០១១ ។

[23] អនុស្សរណៈ: "អង្គភាពគាំពារការការពារក្ដី-សំណើសុំបន្តកិច្ចសន្យា consultancy សម្រាប់ [redacted]" ដោយអ្នកនាង Nisha Valabhji (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្ដី) ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ២០១១ ។

[24] អនុស្សរណៈ: "ការធ្វើយុត្តិកម្មសម្រាប់ការបន្តកិច្ចសន្យារបស់ [redacted]' ដោយអ្នកនាង Nisha Valabhji (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្ដី) ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១ ។

នៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០១១ អនុប្រធានការិយាល័យរដ្ឋបាលបានបដិសេធសំណើនេះ[25] ។

២៥. បើតាមអង្គភាពគាំពារការការពារក្តីបានដឹង [redacted] មិនទាន់ត្រូវបានអនុញ្ញាតឲ្យពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ នៅឡើយទេ ។

២៦. បើតាមអង្គភាពគាំពារការការពារក្តីបានដឹងជនសង្ស័យនៅក្នុងករណី ០០៤ នៅតែពុំទាន់ទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពនៅឡើយទេ ។

២៧. នៅថ្ងៃទី ៧ ខែ តុលា ឆ្នាំ២០១១ មន្ត្រីទទួលបន្ទុកអង្គភាព DSS ដាក់អនុស្សរណៈដែលមានចំណងជើងថា "អង្គភាពគាំពារការការពារក្តីបង្ហាញបញ្ជីឈ្មោះមេធាវីជាតិនិងមេធាវីអន្តរជាតិដល់ជនសង្ស័យក្នុងករណី ០០៤ ដោយអនុលោមតាមវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុងរបស់ អវតក[26] ដែលនៅក្នុងអនុស្សរណៈ នេះអ្នកនាងបានៈ

i. ជូនដំណឹងជាបន្ទាន់ដល់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតថាអង្គភាពគាំពារការការពារក្តី នឹងខិតខំខ្នែងបង្ហាញបញ្ជីឈ្មោះមេធាវីជាតិ និងមេធាវីអន្តរជាតិដល់ជនសង្ស័យនៅក្នុងករណី ០០៤ ។

ii. ជូនដំណឹងជាបន្ទាន់ដល់ការិយាល័យរដ្ឋបាលថា អង្គភាពគាំពារការការពារក្តីត្រូវការជំនួយផ្នែករដ្ឋបាល និងភស្តុភារ ដើម្បីគាំទ្រដល់ការស្វែងរកជនសង្ស័យនៅក្នុងករណី ០០៤ និងបង្ហាញដល់ពួកគេនូវបញ្ជីឈ្មោះមេធាវី និង

iii. ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតផ្តល់ការិយាល័យរដ្ឋបាលនូវព័ត៌មានណាមួយដែលខ្លួនមាន ឱ្យបានឆាប់បំផុតតាមតែអាចធ្វើបាន ដែលអាចជួយពន្លឿនដំណើរការនេះ ។

---

[25] អនុស្សរណៈអន្តរការិយាល័យៈ "ការចាត់តាំងមេធាវីនៅក្នុងករណី ០០៣ និង ០០៤" ពីលោក Knut Rosandhaug (DDOA) ចុះថ្ងៃទី៩ ខែ កញ្ញា ឆ្នាំ២០១១ ។

[26] អនុស្សរណៈ "អង្គភាពគាំពារការការពារក្តីបង្ហាញបញ្ជីឈ្មោះមេធាវីជាតិ និងមេធាវីអន្តរជាតិដល់ជនសង្ស័យនៅករណី ០០៤ អនុលោមតាមវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុងរបស់ អវតក" ដោយអ្នកនាង Nisha Valabhji (មន្ត្រីទទួលបន្ទុករបស់អង្គភាពគាំពារការការពារក្តី) ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១១ ។

## III. សារណា

### ៣.១អង្គភាពគាំពារការការពារក្តីមានមូលដ្ឋានដើម្បីដាក់ញត្តិនេះនៅចំពោះមុខអង្គបុរេជំនុំជម្រះ

២៨. ភាគីទាំងអស់ដែលផលប្រយោជន៍របស់ខ្លួន ត្រូវបានប៉ះពាល់ជាអវិជ្ជមានដោយដំណើរការនីតិវិធី មានសិទ្ធិធ្វើសារណាឆ្លើយតបទៅនឹងការដាក់ឯកសាររបស់ភាគីដទៃទៀត[27]ឬដាក់សំណើសុំមោឃភាពនីតិវិធី[28] ឬដាក់សំណើសមហេតុផលសុំពន្យាពេលវេលាកំណត់[29] និងចំនួនសន្លឹក[30] ដែលចាំបាច់ដើម្បីធានាដល់ដំណើរការនីតិវិធីនៅចំពោះមុខ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង ។

២៩. ក្នុងពេលរង់ចាំការចាត់តាំងមេធាវីផ្ទាល់ខ្លួន ដើម្បីតំណាងឱ្យជនសង្ស័យនីមួយៗនៅក្នុងករណី 00៤ ឬការបន្តកិច្ចសន្យាឱ្យលោក គង់ សំអុន ដូច្នេះមន្ត្រីទទួលបន្ទុកអង្គភាព DSS ជាតំណាងជាក់ស្តែង *(De facto)* នៃផលប្រយោជន៍រួមរបស់ជនសង្ស័យ ។ ចំណុចនេះត្រូវបានគាំទ្រដោយការដែលថាអង្គបុរេជំនុំជម្រះបានដាក់បញ្ចូលមន្ត្រីទទួលបន្ទុកអង្គភាព DSS ជាភាគីនៃដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅក្នុងករណី 00៣[31]។

៣០. អង្គបុរេជំនុំជម្រះបានយល់ឃើញពីលើកមុនថាសំណើសុំផ្អាកនីតិវិធី អាចស្ថិត"នៅក្នុងដែនកំណត់ទូទៅនៃពាក្យបណ្តឹងណាមួយដែលស្ថិតនៅក្រោមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ច្បាប់បង្កើតអវតក") ដែលក្នុងនោះចែងពាក់ព័ន្ធថា "ការជំនុំជម្រះត្រូវតែយុត្តិធម៌" និងត្រូវតែប្រព្រឹត្តទៅ "ដោយគោរពយ៉ាងពេញលេញទៅលើសិទ្ធិរបស់ជន

---

[27] មាត្រា ៨.៣ និង ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក ។ (អវតក/0១/២00៧/វិសោធនកម្មលើកទី៦) ។

[28] វិធាន ៧៦ នៃវិធានផ្ទៃក្នុង ។

[29] វិធាន ៣៩(៤)(ក) នៃវិធានផ្ទៃក្នុង ។

[30] មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក (អវតក/0១/២00៧/វិសោធនកម្មលើកទី៦)។

[31] 00៣/0៧-0៩-២00៩-កសចស(អបជ0២) "ការជូនដំណឹងដល់ភាគីពាក់ព័ន្ធនឹងសំណើរបស់សហមេធាវីសុំពន្យាពេលដាក់បណ្តឹងឧទ្ធរណ៍ ដោយរង់ចាំការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង" ឯកសារ D11/2/4/3 (ERN 00714762), ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២0១១ ។

00746717



ជាប់ចោទ..."[32] ។

៣១. សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថាពួកគេចាត់ទុកថា "គោលការណ៍ច្បាប់ដែលអនុវត្តចំពោះសំណើសុំមោឃៈភាព និងច្បាប់ដែលអនុវត្តចំពោះសំណើសុំផ្អាកនីតិវិធី គឺដូចគ្នា ជាពិសេសសំណើទាំងពីរនេះផ្អែកលើអង្គហេតុតែមួយ" ហើយដូច្នេះ ការផ្អាកដំណើរការនីតិវិធីអាចអនុញ្ញាតនៅករណីមានកំហុសនីតិវិធី ឬនឹងកើតឡើងនូវកំហុសនីតិវិធី បើសិនការផ្អាកដំណើរការនីតិវិធីមិនត្រូវបានអនុញ្ញាតនោះ និង"នៅពេលដែលកំហុសនីតិវិធីរំលោភលើសិទ្ធិរបស់ភាគីដែលដាក់សំណើសុំ"[33]។

៣២. ការសំអាងហេតុស្រដៀងនេះ ត្រូវបានប្រើនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី("ICTY") ដើម្បីបង្គាប់ឱ្យផ្អាកនីតិវិធី ជាពិសេសក្នុងករណីដែលការជំនុំជម្រះក្តីដោយយុត្តិធម៌មិនអាចសម្រេចទៅបានដោយគ្មានការផ្អាកនីតិវិធីនោះ[34] ឬនៅករណីដែលការបន្តនីតិវិធី នឹងរំលោភដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ[35] ។

៣៣. អនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងមាត្រា៣៣ថ្មី និងមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីបានសម្រេចថាការផ្អាកដំណើរការនីតិវិធីនៅក្នុងករណី ០០៤ នៅចំពោះមុខអង្គបុរេជំនុំជម្រះ គឺចាំបាច់ដើម្បីឱ្យអង្គភាពគាំពារការការពារក្តីដោយមានការគាំទ្រពីការិយាល័យរដ្ឋបាល ចាត់វាល់វិធានការចាំបាច់ទាំងអស់ដើម្បីឱ្យជនសង្ស័យ

---

[32] ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៤២) "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធិ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធចោលសំណើសុំផ្អាកនីតិវិធីដោយមូលដ្ឋាននៃការរំលោភដំណើរ (D264/1) ឯកសារ D264/2/1 (ERN 00543789) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ នៅកថាខណ្ឌទី១៣ ។

[33] ០០២/១៩-០៩-២០០៧-អវតក/កសចស "ដីកាបដិសេធលើសំណើសុំមោឃៈភាព និងសំណើសុំផ្អាកដំណើរការនីតិវិធីដោយមូលហេតុរំលោភដំណើរការ ដាក់ដោយ អៀង ធិរិទ្ធ" ឯកសារ D264/1 (ERN 00422607-00422618) នៅកថាខណ្ឌទី៣០-ការដាក់ឯកសារសម្ងាត់ដែលសំអាងនៅក្នុង ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៧១) "បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធមិនទទួលយកការដាក់ចម្លើយតបរបស់ អៀង សារី ទៅនឹងសារណាតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា និងការកត់សម្គាល់បន្ថែម និងសំណើសុំផ្អាកនីតិវិធី" ឯកសារ D390/1/2 (ERN 00598685) ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ នៅកថាខណ្ឌទី៣ អក្សរក្នុងលេខយោងលេខ ៦ ។

[34] រឿងក្តីរវាងរដ្ឋអាជ្ញា តទល់ *Dusko Tadic,* IT-94-1-A, "សាលក្រម" តុលាការកំពូលចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ នៅកថាខណ្ឌទី៥៥ ។

[35] រឿងក្តីរវាងរដ្ឋអាជ្ញា តទល់ *Janko Bobetko,* IT-02-62-AR54ស្ទួន, "សេចក្តីសម្រេចលើការជំទាស់ដោយក្រូអាតទៅនឹងសេចក្តីសម្រេច និងដីកាសម្រេចពីការបញ្ជាក់គាំទ្រចៅក្រម" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ នៅកថាខណ្ឌទី១៥ ។

ក្នុងករណី ០០៤ អនុវត្តសិទ្ធិស្របច្បាប់របស់ពួកគេក្នុងការទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាព ។

## ៣.២ ជនសង្ស័យនៅក្នុងករណី ០០៤ មានសិទ្ធិជាមូលដ្ឋានទទួលបានការតំណាងផ្នែកច្បាប់:

៣៤. ជនសង្ស័យនៅក្នុងករណី០០៤ មានសិទ្ធិជាមូលដ្ឋានទទួលបានការតំណាងផ្នែកច្បាប់ អនុលោមតាមច្បាប់បង្កើត អវតក[36] វិធានផ្ទៃក្នុង[37]និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[38](“ICCPR”) ដែលដាក់បញ្ចូលនៅក្នុងក្របខណ្ឌច្បាប់របស់[39]អវតក និងរដ្ឋធម្មនុញ្ញកម្ពុជា[40]

៣៥. មាត្រា ២៤ នៃច្បាប់បង្កើត អវតក ចែងថា:

> *ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារក្តីពីមេធាវី ដែលជ្រើសរើសដោយខ្លួនឯងដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ដល់ “ពួកគេដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយ និងយល់បាន ។* (បញ្ជាក់បន្ថែម) ។

៣៦. វិធាន ២១(១) នៃវិធានផ្ទៃក្នុងធានាថា “*ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់* [...] ត្រូវបានការពារដោយមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន” (បញ្ជាក់បន្ថែម) ។

៣៧. ម្យ៉ាងទៀតវិធាន២១(១)នៃវិធានផ្ទៃក្នុងចែងថា “បទបញ្ញត្តិទាំងអស់នៅជាធរមានត្រូវតែបកស្រាយក្នុងន័យការពារ *ជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនត្រូវចោទ និង ជនរងគ្រោះ”* (បញ្ជាក់បន្ថែម”) ។

៣៨. នៅក្នុងសន្ទានុក្រមរបស់វិធានផ្ទៃក្នុង, “ជនសង្ស័យ” ត្រូវបានកំណត់និយមន័យថាជាបុគ្គលដែលសហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេត ចាត់ទុកថាធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិត

---

[36] មាត្រា ២៤, ៣៣ថ្មី និងមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក ។

[37] វិធាន ២១ នៃវិធានផ្ទៃក្នុង ។

[38] មាត្រា ១៤ និង មាត្រា១៥ ICCPR ។

[39] មាត្រា ៣៣ថ្មី និង មាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក, មាត្រា ១២ និង មាត្រា ១៤ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀង”) ។

[40] មាត្រា ៣១ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។

នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ ។

៣៩. បន្ថែមពីលើនេះ មាត្រា ៣៣ថ្មី នៃច្បាប់បង្កើត អវតក អនុវត្តចំពោះដំណើរការនីតិវិធីទាំងអស់នៅ អវតក បទដ្ឋានអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា១៤ និងមាត្រា ១៥ នៃកតិកាសញ្ញា ICCPR ខណៈដែលមាត្រា ៣៥ថ្មីចែងពីការធានាជាអប្បបរមានៃការជំនុំជម្រះដោយយុត្តិធម៌ ដែលរួមបញ្ចូលៈ

> ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន ។
>
> មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន ដែលជ្រើសរើសដោយខ្លួនឯង ។
>
> ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ និងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ និងទទួលបាននូវជំនួយផ្នែកច្បាប់ដោយឥតថ្លៃ ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលដោយខ្លួនឯង[41]។

៤០. មានការទទួលស្គាល់ថាក្នុងប្រព័ន្ធច្បាប់ស៊ីវិល ការការពារពេញលេញចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺយកមកអនុវត្តចាប់តាំងពីពេលដែលជនសង្ស័យប្រឈមនឹង"ការចោទប្រកាន់"។ សន្ទានុក្រមនៃវិធានផ្ទៃក្នុងបានឲ្យនិយមន័យ "ជនត្រូវចោទ" ថាជា"បុគ្គលម្នាក់ដែលត្រូវចោទប្រកាន់ចំពោះរឿងក្តីណាមួយក្នុងចន្លោះពីពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់"។

៤១. សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា "បុគ្គលណាមួយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវចាត់ថាជា "ជនត្រូវចោទ"[42] ។ ជំហរនេះស៊ីចង្វាក់ជាមួយយុត្តិសាស្ត្របារាំងដែលលើកមកសំអាងដោយសហចៅក្រមស៊ើបអង្កេត[43] ។

---

[41] មាត្រា ៣៥ថ្មី(ក), (ខ) និង(ឃ) នៃច្បាប់បង្កើត អវតក ។

[42] ០០២/១៩-០៩-២០០៧-អវតក-កសចស, "ដីកាបដិសេធសំណើសុំចោទប្រកាន់បន្ថែម, សហចៅក្រមស៊ើបអង្កេត, ឯកសារ D298/2 (ERN 00476085), ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌទី១៣ (ជើងទំព័រទី៦) ។

[43] [...] បុគ្គលណាមួយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទោះបីជានៅពេលដែលគាត់ត្រូវបានចាត់ទុកថាជា "x ដែលត្រូវបង្ហាញខ្លួនជា..." គឺត្រូវបានចាត់ទុកជាជនត្រូវចោទដោយស្វ័យប្រវត្តិ ដោយមិនគិតពីថ្ងៃដែលបុគ្គលនោះត្រូវ

៤២. ការយកមកអនុវត្តទស្សនទាន "ការចោទប្រកាន់" មានឫសគល់នៅក្នុងបរិបទសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[44]។តុលាការអឺរ៉ុបសិទ្ធិមនុស្ស("EctHR")យល់ឃើញថា

> "ចំណុចដ៏លេចធ្លោនៅក្នុងសង្គមប្រជាធិបតេយ្យតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គាំទ្រដល់ការយល់ឃើញនៃ "ការចោទប្រកាន់" ជាក់ស្តែង ជាជាង "ការចោទប្រកាន់" "ផ្លូវការ" ដែលមានយោងនៅក្នុងមាត្រា៦ ។ វាបង្ខំឲ្យតុលាការពិនិត្យមើលឲ្យហួសពីអាការៈពីខាងក្រៅ និងពិនិត្យពីតថភាពរបស់នីតិវិធីដែលជាចោទជាបញ្ហា ដើម្បីសម្រេចថាតើមានការចោទប្រកាន់មាននៅក្នុងអត្ថន័យនៃមាត្រា ៦ ដែរ ឬអត់[45] ។

៤៣. អនុលោមតាមយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសិទ្ធិមនុស្ស ស្ថានភាពរបស់ជនសង្ស័យបំពេញបានទស្សនទាន "ការចោទប្រកាន់" ជាក់ស្តែង សម្រាប់គោលបំណងនៃការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ប្រសិនបើ៖

ក. ការជូនដំណឹងជាផ្លូវការដោយអាជ្ញាធរមានសមត្ថកិច្ចអំពីការចោទប្រកាន់ទៅបុគ្គលម្នាក់ដែលថាគាត់បានប្រព្រឹត្តបទល្មើស ឬ

ខ. មានលេចឡើងនូវវិធានការដទៃទៀតដែលថ្លែងបញ្ជិតបញ្ជៀងដល់ការចោទប្រកាន់ ហើយដែលបានប៉ះពាល់ជាដុំកំភួនដល់ស្ថានភាពរបស់ជនសង្ស័យ[46]។

៤៤. យោងតាមលក្ខខណ្ឌ (ខ) ដែលអាចត្រូវបានបំពេញដោយឯករាជ្យពីអត្ថិភាពនៃ"ការជូនដំណឹងជា

---

បានជូនដំណឹងអំពីការចោទប្រកាន់ដោយចៅក្រមស៊ើបអង្កេតឡើយ""Crim. 5 nov. 1985: Bull. Crim. No 244; D. 186. IR. 303, obs. Pradel; JCP 1986 II. 20685 កត់សម្គាល់ [ការបកប្រែរបស់] Jeandidier៖ ដែលបានសំអាងក្នុងសំណុំរឿង 002/19-09-2007-អវតក-កសចស, "ដីកាបដិសេធសំណើសុំចោទប្រកាន់បន្ថែម, សហចៅក្រមស៊ើបអង្កេត, ឯកសារ D298/2 (ERN 00476085), ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌទី១៣ (ជើងទំព័រទី៦) ។

[44] សូមមើលផងដែរ Stephanos Stavros "ការធានាចំពោះជនសង្ស័យដែលត្រូវចោទប្រកាន់ក្រោមមាត្រា៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស៖ការវិភាគអំពីការអនុវត្តន៍សិទ្ធិសញ្ញា និងការប្រៀបធៀបជាមួយលិខិតុបករណ៍ដទៃទៀត" Martinus Nijhoff, Dordrecht, 1993, នៅទំព័រ ៨៣ "អនុសញ្ញាមានបំណងការពារបុគ្គលប្រឆាំងនឹងការដែលមានការសង្ស័យជាដុំកំភួនប្រឆាំងនឹងគាត់ក្នុងរយៈពេលយ៉ាងយូរដោយមិនសមហេតុផលនិងដោយគ្មានការសម្រេចអ្វីសោះ ។ ការចេះតែសង្ស័យបែបនេះ ជាពិសេសប្រសិនបើវាសាយភាយដល់សាធារណៈជន វាបង្កឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍, សតិអារម្មណ៍ ព្រមទាំងសម្ភារៈ និងមនុស្សក្នុងក្រុមគ្រួសាររបស់គាត់ ។

[45] រឿងក្តី Adolf តទល់នឹងប្រទេស Austria (១៩៨២) 4 EHRR 313 នៅកថាខណ្ឌទី៣០ ។

[46] រឿងក្តី Adolf ទល់នឹងប្រទេស Austrial (១៩៨២) 4EHRR 313, កថាខណ្ឌទី៣០។

ផ្លូវការ" ដូច្នេះពាក្យថា "ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" សំដៅដល់ផលលំបាកដែលបង្កឡើងដោយសកម្មភាពចោទប្រកាន់ និង/ឬសកម្មភាពស៊ើបអង្កេត ទៅលើផលប្រយោជន៍បុគ្គល និងផលប្រយោជន៍ផ្នែកច្បាប់របស់ជនសង្ស័យ[47]។

៤៥. កត្តាទាំងខាងក្រោមនេះ បាននាំឱ្យមានការលើកឡើងដោយប្រយោលអំពីការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌប្រឆាំងជនសង្ស័យក្នុងករណី ០០៤ ហើយប៉ះពាល់យ៉ាងខ្លាំងដល់ផលប្រយោជន៍របស់ពួកគេ៖

ក. ជនសង្ស័យនៅក្នុងករណី ០០៤ ត្រូវបានប្រព័ន្ធផ្សព្វផ្សាយលើកឡើងជាច្រើនលើកច្រើនសារ[48]។ អត្តសញ្ញាណរបស់ពួកគេត្រូវបានបញ្ជាក់តាមរយៈការចុះផ្សាយឯកសារផ្លូវការរបស់តុលាការដែលបានបែកធ្លាយ[49] និងនៅក្នុងសេចក្តីថ្លែងការជាសាធារណៈដោយ

---

[47] *Eckle ទល់នឹងប្រទេសអាល្លឺម៉ង់* ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨២ នៅកថាខណ្ឌទី៧៤ដែលនៅទីនោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានប្រកាន់ខ្ជាប់ដើម្បីយកទៅអនុវត្ត មិនត្រឹមតែនៅពេលមានការជូនដំណឹងជាផ្លូវការអំពីបទចោទប៉ុណ្ណោះទេ ប៉ុន្តែចាប់តាំងពីការចាប់ផ្តើមស៊ើបអង្កេតបឋមផងដែរ ។

[48] Robbie Correy-Boulet and May Titthara, កម្មាភិបាលជាច្រើនរូបប្រឈមមុខនឹងការចាប់ខ្លួន 'Cadres face prospect of more arrests', *ឌឹ ភ្នំពេញប៉ុស្តិ៍* ចេញផ្សាយនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។ Julia Wallace "តុលាការដកវិញនូវការប្រកាសការចាត់តាំងមេធាវីការពារក្តីថ្មី" 'Tribunal retracts announcement of new defence lawyer', *The Cambodia Daily*, ចុះផ្សាយថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០។ T. Curvallier, "ជនសង្ស័យប្រាំនាក់បន្ថែមទៀតនៅទីក្រុងភ្នំពេញ" វិទ្យុ *Radio Nederland Wereldomroep*, ចេញផ្សាយនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ (ERN 00411534) ។

[49] J. Ferrie, ឯកសារបែកធ្លាយបង្កឱ្យមានមន្ទិលលើអនាគតិរបស់ចៅក្រមនៅសាលាក្តីខ្មែរក្រហម, The Christian Science Monitor, ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១, (អាចរកបាននៅគេហទំព័រ:www.scmonitor.com/layout/set/print/content/view/print/390529) Julia.Wallace, " ក្រោមសំពាធ សាលាក្តីខ្មែរក្រហមបញ្ចេញបញ្ជី" Under Pressure, Tribunal Release List", *ព្រឹត្តិប័ត្រ ឌឹកាំបូដាលី* ចេញផ្សាយនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១១ នៅទំព័រ២៧ ។ J. Ferrie, " ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ស្ថិតនៅភាពមិនប្រាកដប្រជាផ្នែកច្បាប់" (Khmer Rouge crimes in legal limbo) The *National*, ២៤ ខែមិថុនា ឆ្នាំ២០១១។ S. Manning, "ឯកសារដែលត្រូវបានគេលួចបញ្ចេញ លើកឡើងពីការឈប់គាំទ្រដល់ការជំនុំជម្រះពួកខ្មែរក្រហមដោយអង្គការសហប្រជាជាតិ" Scoop, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ (អាចរកបាននៅ: http://www.scoop.co.nz/stories/HL1106/ S00165/leaked-documents-suggest-un-backing-off-khmer-rouge-trials.htm)

ប្រធានផ្នែកកិច្ចការសារធារណៈស្ដីទីរបស់ អវតក[50]។ យ៉ាងហោចណាស់ក៏មានជនសង្ស័យពីរនាក់ដែរដែលត្រូវបានសម្គាសន៍ដោយសារព័ត៌មាន និងបានធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈទាក់ទងនឹងតួនាទីរបស់ពួកគេក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អវតក និងបានអធិប្បាយពីការចោទប្រកាសន៍ដែលត្រូវបានគេលួចបញ្ចេញប្រឆាំងនឹងពួកគេ និងបានសម្ដែងក្ដីកង្វល់ពីលទ្ធភាពនៃការចោទប្រកាន់[51]។ អង្គការក្រៅរដ្ឋាភិបាលមួយបានធ្វើការស៊ើបអង្កេតស្របគ្នាជាសាធារណៈ ដោយបានផ្សព្វផ្សាយនូវខ្លឹមសារនៃការសម្ភាសន៍សាក្សីសក្ដានុពលមួយចំនួន ទាក់ទងនឹងទីតាំងបទល្មើសនានាដែលស្ថិតនៅក្រោមការស៊ើបអង្កេតនៅក្នុងករណី 00៤ នៅឡើយ[52] ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានផ្សាយបញ្ជីលំអិតអំពីការចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យនីយមួយៗ និងបានអះអាងថាពួកគេឋិតនៅក្នុងយុត្តាធិការរបស់ អវតក[53] ។ កត្តាទាំងនេះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មាន

---

[50] Kong Sothanarith “អ្នកដាក់ពាក្យសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនៅសាលាក្ដីខ្មែរក្រហមបង្ហាញជនសង្ស័យបីនាក់បន្ថែម” វិទ្យុ VOA ជាភាសាខ្មែរ ចុះថ្ងៃទី២0 ខែមិថុនា ឆ្នាំ២០១១ ដែលបានដកស្រង់សំដីរបស់មន្ត្រីតុលាការថាអ្នកដាក់ពាក្យសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី សេង ធារី “រំលោភបំពានគោលការណ៍សម្ងាត់ ដោយបាននិយាយចំឈ្មោះជនសង្ស័យ” ។

[51] Sok Skemara “ជនសង្ស័យទីពីររបស់តុលាការបដិសេធការចោទប្រកាន់របស់ព្រះរាជអាជ្ញា” VOA KHMER, ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ ។ Sok Skemara “ជនសង្ស័យក្នុងអំពើព្រៃផ្សៃនិយាយថា គាត់មិនខ្លាចតុលាការទេ ហើយគាត់ក៏មិនខ្លាចយមរាជដែរ, VOA ភាសាខ្មែរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ ។ M. Tithara & T. Miller, “ជនសង្ស័យពីឧក្រិដ្ឋសង្គ្រាមដែលទ្រុតទ្រោមសុខភាព “មិនខ្លាច” ប្រឈមមុខជាមួយនឹងតុលាការទេ” *ព្រឹត្តិប័ត្រ ឌឹ ភ្នំពេញប៉ុស្ដិ៍* ចេញផ្សាយនៅថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១១។ Sok Skemara “អតីតខ្មែរក្រហមបដិសេធការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម” VOA ភាសាខ្មែរ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១១ ។ Sok Skemara “ពុំមានមន្ត្រីនៅសាលាក្ដីខ្មែរក្រហមមកទាក់ទងគាត់ឡើយ VOA ភាសាខ្មែរ ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០១១ ។

[52] មជ្ឈមណ្ឌលឯកសារកម្ពុជា: គំរោងលើកកំពស់ការទទួលខុសត្រូវ “ខ្មែរក្រហម” ការសម្ភាសន៍ជាបន្តបន្ទាប់អំពីការដ្ឋានសាងសង់ទំនប់ក្រពាំងថ្ម” ថ្ងៃទី១-៥ ខែកក្កដា ឆ្នាំ២០១១ ។

[53] សេចក្ដីប្រកាសព័ត៌មាន “ចៅក្រមស៊ើបអង្កេតគួរលាឈប់ពីមុខតំណែង” Human Rights Watch ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១

ទោសរបស់ជនសង្ស័យ[54] និងសិទ្ធិរបស់ជនសង្ស័យដែលត្រូវទទួលបានការជូនដំណឹងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំនួរ[55]។ កត្តាទាំងនេះបង្កើតឱ្យមានតម្រូវការចាំបាច់ចំពោះការការពារក្ដីប្រកបដោយប្រសិទ្ធិភាពដើម្បីធានាដល់សិទ្ធិទាំងនេះ និងសិទ្ធិទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ផ្សេងទៀត ។

ខ. សិទ្ធិជាមូលដ្ឋានរបស់ជនសង្ស័យចំពោះសមភាពនៃមធ្យោបាយតតាំងក្ដី ត្រូវបាន និងបន្តប៉ះពាល់ដោយការដកមេធាវីការពារក្ដីចេញពីការចូលរួមក្នុងការស៊ើបអង្កេតរយៈពេលពីរឆ្នាំ ព្រមទាំងសិទ្ធិស្នើសុំកិច្ចស៊ើបសួរបន្ថែម សិទ្ធិឆ្លើយតបទៅនឹងសារណារបស់ភាគី ឬបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចដែលធ្វើឡើងក្នុងអំឡុងពេលស៊ើបអង្កេត[56] ។

គ. ការដែលថាបុគ្គលចំនួន [redacted] បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងករណី ០០៤[57] ហើយបើយោងតាមវិធានផ្ទៃក្នុង[58] និងក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រព័ន្ធច្បាប់ស៊ីវិល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលពិនិត្យមើលសំណុំរឿងបាន[59] ដូច្នេះហើយវារឹតតែធ្វើឱ្យប៉ះពាល់បន្ថែមទៀតដល់សមភាពនៃមធ្យោបាយតតាំងក្ដីរបស់ជនសង្ស័យ ដោយមិនបានផ្ដល់ឱ្យពួកគេនូវដំណោះស្រាយជាសិទ្ធិខាងនីតិវិធីដូចក្នុងប្រព័ន្ធច្បាប់ស៊ីវិលដទៃទៀត[60] ។

---

[54] Stavros សូមមើលអក្សរក្នុងលេខយោងលេខ ៤៤ ខាងលើ ។

[55] វិធាន២១(១) (ឃ)នៃវិធានផ្ទៃក្នុង។

[56] សូមមើលកថាខណ្ឌ ៧-១៦ ខាងលើនៃញត្តិនេះ ។

[57] របាយការណ៍តុលាការខែសីហា ឆ្នាំ២០១១ "ផ្នែកកិច្ចការសាធារណៈ លេខ ៣៩ ទំព័រ៥ ។ សូមកត់សំគាល់ថានៅក្នុងសេចក្ដីព័ត៌មានជាបន្តបន្ទាប់ ចំនួនអ្នកដាក់ពាក្យសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីមានតែ ២០០ នាក់: "សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតស្ដីពីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី ០០៤, ការិយាល័យសហាក្រមស៊ើបអង្កេត ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០១១ ។

[58] វិធាន២៣ ស្ទួន(២) នៃវិធានផ្ទៃក្នុង។

[59] មាត្រា ១១៤ កថាខណ្ឌទី៥-១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ។ សូមមើលផងដែរ Frédérique Agostini, 'Les droits de la partie civile dans le proces pénal', Rapport Annuel de la Cour de Cassation, 2000 ។

[60] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំងបានផ្ដល់ដំណោះស្រាយជាឧប្បាស្រ័យនៃវិសមភាពនេះដោយដាក់ឈ្មោះបុគ្គលដែលត្រូវដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីថាជា "ដែលត្រូវបានចោទ" « *Une personne qui a été personnellement mise en cause dans une plainte avec constitution de partie civile et contre laquelle le ministère public a requis, <u>nommément, l'ouverture d'une information est partie à l'instance et doit être considérée comme inculpée</u>* » : សំណើរបស់អង្គភាពគាំពារការការពារក្ដីសុំផ្អាកដំណើរការនីតិវិធីនៅក្នុងករណី ០០៤ នៅចំពោះអង្គបុរេជំនុំជម្រះ និងសុំឱ្យមាន

00746724



៤៦. ដូច្នេះ ជនសង្ស័យក្នុងករណី 00៤ មានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការតំណាងផ្នែកច្បាប់ ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

ក. មាត្រា២៤ នៃច្បាប់ស្តីពីការបង្កើត អវតក ស្របជាមួយ វិធាន២១(១) នៃវិធានផ្ទៃក្នុង និងសន្ទានុក្រមនៃវិធានផ្ទៃក្នុង ចែងយ៉ាងច្បាស់ទាក់ទងនឹងសិទ្ធិទទួលបានការការពារក្តី ដោយខានពុំបានរបស់ជនសង្ស័យ។

ខ. បន្ថែមពីលើនេះ ជនសង្ស័យមានសិទ្ធិទទួលបានតំណាងផ្នែកច្បាប់អនុលោមតាមសិទ្ធិជាមូលដ្ឋានរបស់ពួកគេក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលអាចយកមកអនុវត្ត តាមរយៈការកើតឡើងនៃវិធានការនានាដែលឈានដល់ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌប្រឆាំងជនសង្ស័យ ដែលប៉ះពាល់យ៉ាងខ្លាំងដល់ផលប្រយោជន៍របស់ពួកគេ[61]។

## ៣.៣ ការិយាល័យរដ្ឋបាលនៅ អវតក មានកាតព្វកិច្ចគាំទ្រសិទ្ធិទទួលបានតំណាងផ្នែកច្បាប់របស់ជនសង្ស័យ

៤៧. វិធាន២២(១) នៃវិធានផ្ទៃក្នុងចែងថា៖

ជនណាដែលមានសិទ្ធិទទួលបានមេធាវីស្ថិតនៅក្រោមវិធានផ្ទៃក្នុងនេះ ត្រូវមានសិទ្ធិទទួលបានជំនួយពីមេធាវីជាតិ ឬមេធាវីអន្តរជាតិដោយសហការជាមួយមេធាវីជាតិទៅតាមការជ្រើសរើសដោយផ្ទាល់ខ្លួនរបស់ពួកគេ តាមបែបបទដូចខាងក្រោម:

[...]

ជនក្រីក្រដែលមានសិទ្ធិទទួលបានការតំណាង ឬ ជំនួយតាមផ្លូវច្បាប់ក្រោមវិធានទាំងនេះ ត្រូវមានសិទ្ធិជ្រើសរើស ដោយសេរីពីក្នុងចំណោមមេធាវីជាតិ និងអន្តរជាតិដែលមានក្នុងបញ្ជីដូចមានចែងក្នុងវិធាន ១១(២)(ឃ)។

---

Crim. 24 mai 1971 : Bull. crim. n. 171 ដកស្រង់ Dalloz ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង, បោះពុម្ពផ្សាយឆ្នាំ២00៩, ទំព័រ៣១៤

[61] សូមមើលផងដែរ មាត្រា៥៦(២) (គ) នៃលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទាក់ទងនឹងឱកាសស៊ើបអង្កេតដែលផ្តល់អំណាចឲ្យអង្គបុរេជំនុំជម្រះ ចាត់តាំងមេធាវី "ដើម្បីតំណាងឲ្យផលប្រយោជន៍នៃការការពារក្តី" នៅក្នុងករណីដែលពុំមានការចាប់ខ្លួន ឬ ការចូលខ្លួនរបស់ជនសង្ស័យ ។ លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានផ្តល់សច្ចាប័នដោយ ១១៦ រដ្ឋ ។ សូមមើលផងដែរនៅផ្នែក ១៤0 និង១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាឡឺម៉ង់។

៤៨. ការកំណត់ជាបឋមទាក់ទងនឹងបញ្ហាថាតើបុគ្គលម្នាក់មានសិទ្ធិទទួលបានមេធាវី អនុលោមតាមវិធានផ្ទៃក្នុង គឺជាបញ្ហាសំខាន់ក្នុងការការពារក្តី ដែលស្ថិតនៅក្រោមអាណត្តិស្វ័យភាពរបស់អង្គភាពគាំពារការការពារក្តី ស្របតាមវិធាន ១១(១) នៃវិធានផ្ទៃក្នុង ហើយមិនស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែករដ្ឋបាលឡើយ:

> ការិយាល័យរដ្ឋបាលត្រូវ បង្កើតអង្គភាពគាំពារការការពារក្តីដែលមានស្វ័យភាពលើបញ្ហាសំខាន់ក្នុងការការពារក្តីប៉ុណ្ណោះ ដូចមានចែងក្នុងវិធាននេះ។

៤៩. បទប្បញ្ញត្តិនេះឆ្លុះបញ្ចាំងពីគោលការណ៍ស្ថាបនិកមួយក្នុងចំណោមគោលការណ៍ស្ថាបនិកជាច្រើនទៀតទាក់ទងនឹងរចនាសម្ព័ន្ធរបស់ អវតក ដែលជម្រុញឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងរបាយការណ៍ឆ្នាំ ២០០៤ របស់លោកស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម :

> ប្រព័ន្ធជំនួយផ្នែកច្បាប់របស់អង្គជំនុំជម្រះនឹងត្រូវបានចាត់ចែងដោយអង្គភាពគាំពារការការពារក្តីតូចមួយដែលមានស្វ័យភាពដាច់ពីការិយាល័យរដ្ឋបាល [...][62]។

៥០. អំណាចរបស់មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី ដើម្បីចាត់តាំងមេធាវីមានចែងក្នុងវិធាន ១១(៦) នៃវិធានផ្ទៃក្នុង :

> ប្រធានអង្គភាពគាំពារការការពារក្តីត្រូវសម្រេចអំពីជនណាមួយជាជនក្រីក្រ និងចាត់តាំងមេធាវីការពារជនក្រីក្រ [...]។

៥១. អំណាចនេះត្រូវបានបញ្ជាក់គាំទ្រដោយប្រធានអង្គជំនុំជម្រះសាលាដំបូងនៃ អវតក កាលពីថ្ងៃទី ៦ ខែសីហា ឆ្នាំ២០១០[63]។ យុត្តិសាស្ត្រនៅ អវតក អនុញ្ញាតឱ្យមន្ត្រីទទួលបន្ទុកនៃអង្គភាពគាំពារការការពារក្តីសម្រេចចាត់តាំងមេធាវីការពារក្តី ខណៈពេលដែលអង្គជំនុំជម្រះពាក់ព័ន្ធដទៃទៀតគ្រាន់តែធ្វើការ"កត់សម្គាល់" ពីការចាត់តាំងមេធាវីការពារក្តី "*ដោយឈរលើមូលដ្ឋាននៃសេចក្តីសម្រេច*

---

[62] របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម,A/59/432/ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៤, កថាខណ្ឌទី៣៥។

[63] ០០១/១៨-០៧-២០០៧/អវតក/អជស "ការជូនដំណឹងអំពីការចាត់តាំងសហមេធាវី" អង្គជំនុំជម្រះសាលាដំបូង, ឯកសារ E189 (ERN 00581354) ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១០ : លោក កង ឫទ្ធារី ត្រូវបានចាត់តាំងឱ្យធ្វើជាសហមេធាវីជាតិទី២ ដោយលោក Richard Rogers អតីតប្រធានអង្គភាពគាំពារការការពារក្តី។ ចៅក្រមបានកត់សម្គាល់ពីការតែងតាំងនេះដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចរបស់លោក Richard Rogers។

00746726



*នេះ*'[64] តែប៉ុណ្ណោះ។

៥២. សម្រាប់គោលបំណងទាំងនេះ វិធាន១១(២) នៃវិធានផ្ទៃក្នុងចែងថា[65]:

> អង្គភាពគាំពារការការពារក្តីត្រូវបំពេញមុខងារដូចខាងក្រោម:
>
> [...]
>
> ដោយស្ថិតនៅក្រោមការឃ្លាំមើលរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្រប បង្ហាញបញ្ជីឈ្មោះមេធាវី ដូចមានចែងក្នុងអនុវិធាន ២ ចំណុច (គ)និង(ឃ) ទៅដល់បុគ្គលដែលមានសិទ្ធិទទួលបានមេធាវីការពារក្តី ស្របតាមវិធានផ្ទៃក្នុងនេះ។

៥៣. ជាងនេះទៅទៀត អនុលោមតាមវិធាន១១(២)(ឆ) នៃវិធានផ្ទៃក្នុង :

> អង្គភាពគាំពារការការពារក្តីត្រូវបំពេញមុខងារដូចខាងក្រោម:
>
> [...]
>
> ធ្វើកិច្ចសន្យាជាមួយមេធាវីការពារក្តី ដែលការពារជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ ដែលក្រីក្រ ឬបុគ្គលដទៃទៀតដែលមានសិទ្ធិទទួលបានមេធាវីការពារក្តី ស្របតាមវិធានផ្ទៃក្នុងនេះ ។

៥៤. កិរិយាសព្ទ"ត្រូវ" ដែលប្រើក្នុងបទបញ្ញត្តិទាំងនេះបង្កើតកាតព្វកិច្ចមួយដល់មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីដើម្បីចាត់វិធានការនានា ដើម្បីធានាឱ្យមានការតំណាងផ្នែកច្បាប់ជូនអ្នកដែលមានសិទ្ធិទទួលបានការតំណាងផ្នែកច្បាប់នៅក្រោមច្បាប់នេះ។

៥៥. ដូចក្នុងករណីបច្ចុប្បន្ននេះ នៅពេលដែលមន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីបានកំណត់ដោយអនុលោមតាមបទបញ្ញត្តិនៃក្របខណ្ឌច្បាប់នៅ អវតក ថាបុគ្គលមួយចំនួនមានសិទ្ធិទទួលបានជំនួយពីមេធាវី នោះមន្ត្រីទទួលបន្ទុកមានកាតព្វកិច្ចចាប់ផ្តើមនីតិវិធីជូនដំណឹងដល់បុគ្គលទាំងនោះ

---

[64] *ដូចខាងលើ*។

[65] វាច្បាស់ណាស់ថាពាក្យថា "ស្ថិតក្រោមការឃ្លាំមើល" ក្នុងវិធាន១១ (២)(ង) នៃវិធានផ្ទៃក្នុង គឺគ្រាន់តែចង់ធានាថាការប្រគល់បញ្ជីឈ្មោះមេធាវីទៅឱ្យជនសង្ស័យត្រូវបានធ្វើឡើងដោយត្រឹមត្រូវ និងបានដឹងឮដោយ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលពាក់ព័ន្ធប៉ុណ្ណោះ។

00746727



អំពីសិទ្ធិរបស់ពួកគេ វាយតម្លៃពីភាពក្រីក្ររបស់ពួកគេដើម្បីសម្រេចថា តើពួកគេមានសិទ្ធិទទួលបានមេធាវីការពារក្តីដែលផ្តល់ថវិការដោយតុលាការ[66]ដែរ ឬទេ និងចាត់តាំងមេធាវីដែលពួកគេជ្រើសរើសដោយខ្លួនឯង តាមករណីសមស្រប ។

៥៦. ជំហានដំបូងក្នុងនីតិវិធីនេះគឺការទំនាក់ទំនងលើកដំបូងដើម្បីកំណត់ថាតើជនសង្ស័យចង់បានមេធាវីដែរឬអត់ ហើយប្រសិនបើជនសង្ស័យចង់បានមេធាវី នោះត្រូវបង្ហាញបញ្ជីឈ្មោះមេធាវី[67] និងវាយតម្លៃពីភាពក្រីក្ររបស់ពួកគេ។

៥៧. តាមរយៈមុខងាររបស់គាត់ជាអ្នកចាត់ចែងធនធានដែលផ្តល់ឱ្យតាមរយៈមូនិធិទំនុកចិត្តរបស់អង្គការសហប្រជាជាតិ[68] **(United Nations Trust Fund)** និងកាតព្វកិច្ចរបស់គាត់ស្របតាមវិធាន ៩(៣) នៃវិធានផ្ទៃ ដើម្បីគាំទ្រមន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីក្នុងការបំពេញមុខងារស្វយ័តរបស់នាង ដោយផ្តល់សម្ភារៈ អគារ បច្ចេកវិទ្យាព័ត៌មានវិទ្យា ពស្តុភារ យានជំនិះ មធ្យោបាយធ្វើដំណើរ និងសេចក្តីត្រូវការផ្នែករូបវន្ត និងរដ្ឋបាល" អនុប្រធានការិយាល័យរដ្ឋបាលមានកាតព្វកិច្ចទទួល និងសម្រួលសំណើរបស់មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីសុំការគាំទ្រផ្នែកសម្ភារៈ និងរដ្ឋបាលដែលចាំបាច់ ដើម្បីបំពេញមុខងារស្វយ័តក្នុងអាណត្តិរបស់នាង ។

៥៨. ការបដិសេធមិនព្រមទទួលយកសំណើរបស់មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីសុំការគាំទ្រផ្នែកសម្ភារៈ និងរដ្ឋបាលដើម្បីធានាឱ្យបាននូវសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានតំណាងផ្នែកច្បាប់ជូនជនសង្ស័យក្នុងករណី ០០៤ នាំឱ្យមានការរំលោភដល់សិទ្ធិរបស់ជនសង្ស័យដែលមានចែងក្នុងវិធាន ២១(១) និងវិធាន ២២(១)(ខ) នៃវិធានផ្ទៃក្នុង ។

**<u>៣.៤ អង្គភាពគាំពារការការពារក្តី ត្រូវការជំនួយជាបន្ទាន់ពីការិយាល័យរដ្ឋបាលដើម្បីទាក់ទងទៅជនសង្ស័យ ដើម្បីកំណត់ថាតើពួកគេចង់បានមេធាវីដែរ ឬទេ និងដើម្បីបង្ហាញដល់ពួកគេនូវបញ្ជីឈ្មោះមេធាវី អនុលោមតាមវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុង។</u>**

៥៩. ទោះបីជាប្រព័ន្ធផ្សព្វផ្សាយបានចុះផ្សាយបញ្ហាជាច្រើនទាក់ទងនឹងករណី ០០៣ និង០០៤ ក៏ជន

---

[66] សូមមើលវិធាន១១ (៦) នៃវិធានផ្ទៃក្នុង។

[67] សូមមើលវិធាន១១ (២) នៃវិធានផ្ទៃក្នុង។

[68] សូមមើលមាត្រា៣១ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក។

សង្ស័យនៅក្នុងករណី ០០៤ អាចមិនដឹងអំពីប្រការដែលថាពួកគេមានសិទ្ធិទទួលបានជំនួយពីមេធាវីដែលផ្ដល់ថវិកាដោយតុលាការ បើសិនជាពួកគេគ្មានមធ្យោបាយបង់ប្រាក់សម្រាប់ការតំណាងផ្នែកច្បាប់ដោយខ្លួនឯងទេនោះ។ វាជាសិទ្ធិស្របច្បាប់របស់ពួកគេក្នុងការទទួលបានការជូនដំណឹងពីសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ។

៦០. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដី មិនមានព័ត៌មានពិស្ដារដែលចាំបាច់ដើម្បីជូនដំណឹងជនសង្ស័យអំពីសិទ្ធិរបស់ពួកគេឡើយ ។ ជាងនេះទៅទៀត ដោយសារតែវេទយិតភាពរបស់បញ្ហានេះ និងក្ដីបារម្ភផ្នែកសន្តិសុខ ដោយផ្អែកលើបរិបទនយោបាយទាក់ទងនឹងដំណើរការនីតិវិធីទាំងនេះ ក៏ដូចជាមធ្យោបាយធ្វើដំណើរ និងតម្រូវការផ្នែកសម្ភារៈដទៃទៀតដែលពាក់ព័ន្ធនឹងការបំពេញមុខងាររបស់នាងស្របតាមវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុង មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដី ត្រូវការជំនួយជាបន្ទាន់ពីការិយាល័យរដ្ឋបាល ដើម្បីទាក់ទងទៅជនសង្ស័យ ជូនដំណឹងដល់ពួកគេអំពីសិទ្ធិរបស់ពួកគេ និងបង្ហាញពួកគេនូវបញ្ជីឈ្មោះមេធាវី ។

៦១. នៅក្នុងករណីដែលការិយាល័យរដ្ឋបាលមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីជួយអង្គភាពគាំពារការការពារក្ដីក្នុងការបំពេញអាណត្តិរបស់ខ្លួនក្រោមវិធាន ១១(២)(ង)ទេ ដូច្នេះព័ត៌មានបែបនេះត្រូវតែបានផ្ដល់មកការិយាល័យរដ្ឋបាលដោយអង្គភាពពាក់ព័ន្ធទាំងអស់ ។

<u>៣.៥ នៅដំណាក់ការអន្តរកាលនេះ អនុប្រធានការិយាល័យរដ្ឋបាលត្រូវតែបន្តកិច្ចសន្យាការងារជូន</u> [redacted]

៦២. នីតិវិធីធម្មតាសម្រាប់ចាត់តាំងមេធាវីដែលមានចែងក្នុងកថាខណ្ឌ ៦.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី[69] ("បទបញ្ជារដ្ឋបាលអង្គភាពគាំពារការការពារក្ដី") តម្រូវឱ្យអង្គភាពនេះទាក់ទងទៅជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទដែលមានសិទ្ធិទទួលបានការតំណាងដើម្បីវាយតម្លៃមធ្យោបាយហិរញ្ញវត្ថុរបស់ពួកគេ បង្ហាញពួកគេនូវបញ្ជីឈ្មោះមេធាវីជាតិ និងមេធាវីអន្តរជាតិ និងផ្ដល់ឱ្យពួកគេនូវ "ទម្រង់សំណើសុំការចាត់តាំងមេធាវី" ដែលត្រូវអនុម័តដោយអង្គភាពគាំពារការការពារក្ដី និងបញ្ជូនបន្តជាការជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប ។

៦៣. ក្នុងករណីមានការពន្យារដំណើរការដែលមានចែងនៅកថាខណ្ឌ ៦.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គ

[69] អនុម័ត កាលពីខែកក្កដា ឆ្នាំ២០០៧, អនុលោមតាមវិធាន១១(២) (ក) (ii) នៃវិធានផ្ទៃក្នុង។

ភាពគាំពារការការពារក្តី កថាខណ្ឌ ៦.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពនេះបានចែងពីការចាត់តាំងជាបណ្តោះអាសន្ននូវមេធាវីការពារក្តីដល់ចុងចោទ ដែលត្រូវការតំណាងរហូតទល់តែសហមេធាវីត្រូវបានចាត់តាំងជាអចិន្ត្រៃយ៍[70]។

៦៤. យន្តការណ៍នេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានដើម្បីជ្រើសរើស[redacted] និងឆ្លុះបញ្ចាំងពីច្បាប់ និងការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[71]។ អនុលោមតាមមាត្រា៣៣ថ្មី នៃច្បាប់បង្កើត អវតក នីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិអាចត្រូវលើកយកមកធ្វើជាសំអាងក្នុងករណីដែលមានចន្លោះប្រហោងក្នុងនីតិវិធីដែលមានស្រាប់ ឬក្នុងករណីដែលមានមន្ទិលសង្ស័យកើតឡើងទាក់ទងនឹងការបកស្រាយ ឬភាពស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ។

៦៥. តបតាមសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានតំណាងផ្នែកច្បាប់ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដទៃទៀតដែលមានចែងក្នុងច្បាប់បង្កើត អវតក វិធានផ្ទៃក្នុង និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កិច្ចសន្យារបស់[redacted] ត្រូវតែបន្តដើម្បីផ្តល់លទ្ធភាពឲ្យអង្គភាពគាំពារការការពារក្តី អាចធានាបាននូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនសង្ស័យ ដែលរង់ចាំការចាត់តាំងមេធាវីការពារក្តី អនុលោមតាមវិធាន ២២(១)(ខ) នៃវិធានផ្ទៃក្នុង។

## ៣.៦ ដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវតែផ្អាកដើម្បីចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីរក្សាឲ្យបាននូវសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានតំណាងផ្នែកច្បាប់

៦៦. ដំណើរការនីតិវិធីនៅក្នុងករណី 004 តម្រូវឲ្យមានការចូលរួមពីមេធាវីការពារក្តី ព្រោះជនសង្ស័យមានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាព ។

៦៧. ការបន្តដំណើរការនីតិវិធីទាំងនេះដោយគ្មានការចូលរួមពីមេធាវីការពារក្តី នឹងរំលោភបំពានលើផ្នែកជាច្រើននៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានសមភាពនៃមធ្យោ

---

[70] កថាខណ្ឌ៦.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី "ប្រសិនបើមានការពន្យាក្នុងដំណើរការចាត់តាំងមេធាវី ហើយជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ត្រូវការការពារក្តី អង្គភាពគាំពារការការពារក្តីអាចចាត់តាំងមេធាវីបណ្តោះអាសន្នម្នាក់ ឬលើសពីមួយនាក់ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះមេធាវី រហូតទល់តែមានការចាត់តាំងមេធាវីជាអចិន្ត្រៃយ៍"។

[71] សូមមើលឧទាហរណ៍មាត្រា៥៦(២) (គ) នៃលក្ខន្តិកៈទីក្រុងរ៉ូម និងបទបញ្ជា៧៦នៃបទបញ្ជារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

បាយតតាំងក្តី សិទ្ធិទទួលបានការតំណាងប្រកបដោយប្រសិទ្ធិភាព និងសិទ្ធិទទួលបានគោលការណ៍ចំពោះមុខដែលមានចែងក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង។

៦៨. ដូច្នេះ ដំណើរការនីតិវិធីត្រូវតែផ្អាក ដើម្បីឱ្យអង្គភាពគាំពារការការពារក្តី ដោយមានការគាំទ្រពីការិយាល័យរដ្ឋបាល និងអង្គភាពពាក់ព័ន្ធទាំងអស់ ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ជនសង្ស័យក្នុងការទទួលបានការតំណាងផ្នែកច្បាប់ សម្រាប់គោលបំណងនៃដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ ។

## V. ដំណោះស្រាយ

៦៩. អាស្រ័យលើមូលហេតុដូចដែលបានគូសបញ្ជាក់ពីខាងលើ:

ក. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី សូមស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះផ្អាកដំណើរការនីតិវិធីនៅចំពោះមុខខ្លួន ដើម្បីអនុញ្ញាតឱ្យអង្គភាពគាំពារការការពារក្តីដោយមានជំនួយពីការិយាល័យរដ្ឋបាល ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីផ្តល់ការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពដល់ជនសង្ស័យក្នុងករណី ០០៤ ។

ខ. មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី សូមស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះបង្គាប់ឱ្យការិយាល័យរដ្ឋបាលផ្តល់ជំនួយផ្នែកសម្ភារៈ ហិរញ្ញវត្ថុ និងរដ្ឋបាលដល់អង្គភាពគាំពារការការពារក្តីដែលត្រូវការជាចាំបាច់ ដើម្បីទាក់ទងទៅជនសង្ស័យ និងបង្ហាញពួកគេនូវបញ្ជីឈ្មោះមេធាវី ដូចមានចែងក្នុងវិធាន ១១(២)(ង) នៃវិធានផ្ទៃក្នុង សម្រាប់ដំណើរការនីតិវិធីនៅចំពោះអង្គបុរេជំនុំជម្រះ ។ មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីសូមស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះផ្តល់ការិយាល័យរដ្ឋបាលនូវព័ត៌មានណាមួយដែលខ្លួនមាន ដើម្បីពន្លឿនដំណើរការនេះ ។

គ. នៅដំណាក់ការអន្តរកាលនេះ មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តីសូមស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះចេញដីកាបង្គាប់ឱ្យអនុប្រធានការិយាល័យរដ្ឋបាលឱ្យបន្តកិច្ចសន្យាដល់ [redacted] និង

ឃ. ដោយអនុលោមតាមកម្មវត្ថុនៃតម្លាភាព និងការយល់ដឹងនៃសាធារណជនអំពីដំណើរការយុត្តិធម៌ អង្គភាពគាំពារការការពារក្តីសូមស្នើដោយគោរពឱ្យចាត់ចំណាត់ថ្នាក់ញត្តិនេះជាឯកសារ “សាធារណៈ” [កោសលុប] ។

00746731



០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស (អបជ)

សូមលោក/លោកស្រីចៅក្រមនៃអង្គបុរេជំនុំជម្រះទទួលយកសំណើនេះដោយក្តីគោរព ។

Nisha Valabhji

**មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី**

**ធ្វើនៅភ្នំពេញថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១**